ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម
ការិយាល័យទទួលពាក្យបណ្តឹង និងស៊ើបអង្កេត

# របាយការណ៍ស្តីពីការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប
## (គិតត្រឹមថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៦)

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ខេត្តបាត់ដំបង (លេខកូដ ០២) | | | | | | | | |
| ១ | ០២៥ | ០៦/១០/១៦ | លោកស្រី ម៉េង សុភារី មេធាវីតំណាងឱ្យឈ្មោះ ម៉ាន់ សាមុត ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ឈា នី ជាប្រធានក្រុមប្រឹក្សាឃុំបឹងប្រាំ | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ ឈា នី ជាប្រធានក្រុមប្រឹក្សាឃុំបឹងប្រាំ ពីបទ រារាំងប្រជាពលរដ្ឋមិនឱ្យចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៦ ប្រជាពលរដ្ឋចំនួន ០៣នាក់ ដែលទៅចុះឈ្មោះបោះឆ្នោតដែលមានឈ្មោះ អ៊ុល យ៉ាន់ ភេទស្រី,ឈ្មោះ លី កែវ ភេទប្រុស និងឈ្មោះ ប៉ិត ញ៉ក់ ភេទស្រី ត្រូវបានលោក ឈា នី ប្រធានក្រុមប្រឹក្សាឃុំបឹងប្រាំ មិនព្រមចេញលិខិតបញ្ជាក់ទីលំនៅដើម្បីបម្រើឱ្យការចុះឈ្មោះបោះឆ្នោតទេ។ | ឃុំបឹងប្រាំ ស្រុកបវេល ខេត្តបាត់ដំបង | កំពុងដោះស្រាយ | |
| ២ | ០២៩ | ១៦/១០/១៦ | លោក ផែង ហេង មេធាវីតំណាងឱ្យឈ្មោះ គីម សឿន ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ថោង ញ៉ន ជាប្រធានក្រុមប្រឹក្សាឃុំបឹងរាំង | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ ថោង ញ៉ន ជាប្រធានក្រុមប្រឹក្សាឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ពីបទរារាំងមិនព្រមបញ្ជាក់ទីលំនៅឱ្យពលរដ្ឋដែលអញ្ជើញមកចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦:៣០នាទី ប្រជាពលរដ្ឋម្នាក់បានទៅចុះឈ្មោះបោះឆ្នោតដែលមានឈ្មោះ ខេង លៀប ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៧/០៧/១៩៩៧ ស្នាក់នៅភូមិថ្លុង ឃុំបឹងរាំង ស្រុកកំរៀង | ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង | កំពុងដោះស្រាយ | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្ដឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្ដឹង | ទីកន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | ខេត្តបាត់ដំបង ត្រូវបានលោក ថោង ញ៉ន ជាប្រធានក្រុមប្រឹក្សាឃុំបឹងរាំង មិនព្រមចេញលិខិតបញ្ជាក់ទីលំនៅ ដើម្បីបម្រើឱ្យការចុះឈ្មោះបោះឆ្នោតទេ។ | | | |
| **រាជធានីភ្នំពេញ (លេខកូដ ១២)** | | | | | | | | |
| ១ | ០០១ | ០២/០៩/១៦ | លោក ខេង ពុទ្ធា ជាភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | លោក ទី សុមុនីរ័ត្ន ជាចៅសង្កាត់រងទី២ សង្កាត់ជ័យជំនះ មកពីគណបក្សសម រង្ស៊ី | <u>កម្មវត្ថុ</u>៖<br>ប្ដឹងឈ្មោះ ទី សុមុនីរ័ត្ន ចៅសង្កាត់រងទី២ ស/ក ជ័យជំនះ ពីបទរំខានការចុះឈ្មោះ។<br><u>មូលហេតុ</u>៖<br>លោក ទី សុមុនីរ័ត្ន ជាចៅសង្កាត់រងទី ២ មកពីគណបក្ស សម រង្ស៊ី បានទាមទារបង្កាន់ដៃ ទ.១០២២ និងអត្តសញ្ញាណប័ណ្ណមកកត់ក្នុងសៀវភៅរបស់ខ្លួន ហើយគាត់អះអាងថាទុករាយការណ៍ជូនថ្នាក់លើរបស់គាត់ ដែលប្រព្រឹត្តនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦។ អំពើនេះផ្ទុយពីនីតិវិធី និងតួនាទីចៅសង្កាត់រងទី២ ក្នុងការចុះឈ្មោះបោះឆ្នោត។ | ស/ក ជ័យជំនះ ខ. ដូនពេញ រាជធានីភ្នំពេញ | ដើមបណ្ដឹងដកពាក្យបណ្ដឹង | |
| ២ | ០០២ | ០៣/០៩/១៦ | លោក ទិត សំណាង ជាភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | លោក ស្រី ញាណ សមាជិកក្រុមប្រឹក្សាសង្កាត់ចាក់អង្រែលើ មកពីគណបក្សសម រង្ស៊ី | <u>កម្មវត្ថុ</u>៖<br>ប្ដឹងឈ្មោះ ស្រី ញាណ ចៅសង្កាត់រងទី២ ស/ក ចាក់អង្រែលើ នៃគណបក្ស សម រង្ស៊ី ពីបទអុកឡុករាំងសកម្មភាពជាប្រក្រតីតាមមាត្រា ១៧១ នៃ ច.ប.ឃ.ស ។<br><u>មូលហេតុ</u>៖<br>នៅវេលាម៉ោង ០៧:០៥ ដល់ម៉ោង ០៧:៣៥ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ ស្រី ញាណ បានទៅអង្គុយកន្លែងរបស់ប្រធាន ក.ច.ប ជាហេតុនាំឲ្យ ក.ច.ប មិនអាចធ្វើការចុះឈ្មោះបោះឆ្នោតបាន។ | ស/ក ចាក់អង្រែលើ ខ. មានជ័យ រាជធានីភ្នំពេញ | លិខិតជូនដំណឹង | |
| ៣ | ០០៣ | ០៥/០៩/១៦ | លោក ទី សុមុន្នីរតន៍ | លោកស្រី រឿង ផល្លីន | <u>កម្មវត្ថុ</u>៖<br>ប្ដឹងឈ្មោះ រឿង ផល្លីន ចៅសង្កាត់ ជ័យជំនះ ខ.ដូន | ស/ក ជ័យជំនះ ខ. ដូនពេញ | ចាត់បដិសេធ (ដាក់ក្រោយ | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជាចៅសង្កាត់រងទី២ សង្កាត់ជ័យជំនះនៃគណបក្សសម រង្ស៊ី | ជាចៅសង្កាត់ជ័យជំនះនៃគណបក្សប្រជាជនកម្ពុជា | ពេញ រាជធានីភ្នំពេញ ពីបទរំខានការចុះឈ្មោះ។<br>**<u>មូលហេតុ</u> ៖**<br>លោកស្រី រឿង ផល្លីន ចៅសង្កាត់ជ័យជំនះ ខ.ដូនពេញ រាជធានីភ្នំពេញ បានធ្វើសកម្មភាពដេញដើមបណ្តឹង (ចៅសង្កាត់រងទី២ ប្រចាំការជាមួយ ក.ច.ប) ចេញពីការិយាល័យចុះឈ្មោះបោះឆ្នោត វេលាម៉ោង ១៧:៣០ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ | រាជធានីភ្នំពេញ | អំឡុងពេលដែលច្បាប់កំណត់) | |
| ៤ | ០០៤ | ០៤/០៩/១៦ | លោក ខេង ពុទ្ធា ជាភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | លោក ទី សុមុន្នីរតន៍ ជាចៅសង្កាត់រងទី២ សង្កាត់ជ័យជំនះ មកពីគណបក្សសម រង្ស៊ី | **<u>កម្មវត្ថុ</u> ៖**<br>ប្តឹងឈ្មោះ ទី សុមុន្នីរតន៍ ចៅសង្កាត់រងទី២ ស/ក ជ័យ ជំនះ ពីបទអុកឡុក រាំងការចុះឈ្មោះបោះឆ្នោត។<br>**<u>មូលហេតុ</u> ៖**<br>លោក ទី សុមុន្នីរតន៍ ជាចៅសង្កាត់រងទី ២ មកពីគណបក្ស សម រង្ស៊ី តែងតែដើរចេញពីការិយាល័យចុះឈ្មោះបោះឆ្នោតទៅឈរពិនិត្យ និងណែនាំប្រជាពលរដ្ឋដែលទៅចុះឈ្មោះបោះឆ្នោតអំពីឯកសារ និងរបៀបនៃការចុះឈ្មោះបោះឆ្នោត និងមិនស្តាប់តាមការណែនាំរបស់ចៅសង្កាត់។ | ស/ក ជ័យជំនះ ខ. ដូនពេញ រាជធានីភ្នំពេញ | លិខិតជូនដំណឹង | |
| ៥ | ០០៥ | ១០/០៩/១៦ | លោក ខិន ភ័រិន ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | នគរបាលបង្ក្រាបបាតុកម្ម | **<u>កម្មវត្ថុ</u> ៖**<br>ប្តឹងនគរបាលបង្ក្រាបបាតុកម្ម ពីបទរាំងប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ។<br>**<u>មូលហេតុ</u> ៖**<br>កាលពីថ្ងៃទី០៥ ខែកញ្ញា វេលាម៉ោង ៦:២៥ នាទី ព្រឹក ដល់ម៉ោង ១១:៣០ នគរបាលបានបិទកំណាត់ផ្លូវ ជាតិលេខ២ ត្រង់ចំណុចមុខវត្តចាក់អង្រែក្រោម តែងផ្លូវ ៦០ ដែលធ្វើឲ្យប្រជាពលរដ្ឋមិនអាចធ្វើដំណើរទៅចុះឈ្មោះបោះឆ្នោតបាន។ | ស/ក ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ | លិខិតជូនដំណឹង | |
| ៦ | ០០៦ | ១០/០៩/១៦ | លោក ខិន ភ័រិន ជាភ្នាក់ | នគរបាលបង្ក្រាបបាតុកម្ម | **<u>កម្មវត្ថុ</u> ៖**<br>ប្តឹងនគរបាលបង្ក្រាបបាតុកម្ម ពីបទរាំងប្រជាពលរដ្ឋ | ស/ក ចាក់អង្រែលើ | លិខិតជូនដំណឹង | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | ទីកន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជាតំណាងគណបក្សសង្គ្រោះជាតិ | | ទៅចុះឈ្មោះបោះឆ្នោត ។<br>**<u>មូលហេតុ</u>៖**<br>កាលពីថ្ងៃទី០៥ ខែកញ្ញា វេលាម៉ោង ៦:២៥ នាទី ព្រឹក ដល់ម៉ោង ១១:៣០ នគរបាលបានបិទកំណាត់ផ្លូវ ជាតិលេខ២ ត្រង់ចំណុចមុខអតីតរោងចក្រ MPP ដែលធ្វើឲ្យប្រជាពលរដ្ឋមិនអាចធ្វើដំណើរទៅចុះឈ្មោះបោះ ឆ្នោតបាន។ | ខណ្ឌមានជ័យ រាជធានី ភ្នំពេញ | | |
| ៧ | ០០៩ | ១៣/០៩/១៦ | លោក ភោគ លីណា តំណាងប្រជាពលរដ្ឋ | លោក ចាន់ ពិសិដ្ឋ ចៅសង្កាត់អូរឬស្សី២ និងប្រធាន ក.ច.ប សង្កាត់អូរឬស្សី២ | **<u>កម្មវត្ថុ</u>៖**<br>ប្តឹងឈ្មោះ ចាន់ ពិសិដ្ឋ និងប្រធាន ក.ច.ប សង្កាត់អូរឬស្សី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ ពីបទរារាំងប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត។<br>**<u>មូលហេតុ</u>៖**<br>ថ្ងៃទី០៩ និងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ អ៊ា សុខហុង បានទៅចុះឈ្មោះបោះឆ្នោតនៅសង្កាត់អូរឬស្សី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ ប៉ុន្តែត្រូវបានចៅសង្កាត់ និងប្រធាន ក.ច.ប បដិសេធមិនព្រមចុះឈ្មោះបោះឆ្នោតឲ្យ និងមិនមានចេញ ទ.១០០៩។ ការបដិសេធនេះដោយមូលហេតុថា ឈ្មោះ អ៊ា សុខហុង បានលក់ផ្ទះ និងផ្លាស់ទីលំនៅទៅរស់ទៅសង្កាត់ផ្សេងហើយ។ | ស/ក អូរឬស្សី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ | លិខិតជូនដំណឹង | |
| ៨ | ០១៨ | ១៥/០៩/១៦ | លោកស្រី ទេព ច័ន្ទសុខខែយ៉ា ជាតំណាងឈ្មោះ សាន្ត អៀន ចៅសង្កាត់រងទី២ នៃ | លោក អៀង សុខឃឹម ចៅសង្កាត់អូរឬស្សី៤ | **<u>កម្មវត្ថុ</u>៖**<br>ប្តឹងឈ្មោះ អៀង សុខឃឹម ចៅសង្កាត់អូរឬស្សី៤ ពីបទរារាំងការចុះឈ្មោះបោះឆ្នោត។<br>**<u>មូលហេតុ</u>៖**<br>ថ្ងៃទី១០ ខែកញ្ញា វេលាម៉ោង ១៥:៣០ នាទី ដល់ម៉ោង ១៦:០០ នាទី លោក អៀង សុខឃឹម ចៅសង្កាត់អូរឬស្សី៤ មិនស្ថិតក្នុងសាលាសង្កាត់ដើម្បីចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋ។ | សង្កាត់អូរឬស្សី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ | ចារបដិសេធ (ដាក់ក្រោយអំឡុងពេលកំណត់) | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | គណបក្ស សម រង្ស៊ី | | | | | |
| ៩ | ០១៨ | ២៥/០៩/១៦ | ឈ្មោះ ទន់ សំឡុត តំណាង គង់ ហៀង ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ឡូយ សារឿន ចៅសង្កាត់ទំនប់ទឹក | **កម្មវត្ថុ ៖**<br>ប្តឹងឈ្មោះ ឡូយ សារឿន ចៅសង្កាត់ទំនប់ទឹក ពីបទមិនបំពេញតួនាទីក្នុងម៉ោងរដ្ឋបាល។<br>**មូលហេតុ ៖**<br>ថ្ងៃទី២១ ខែកញ្ញា វេលាម៉ោង ៧:៣០ នាទី ដល់ ម៉ោង ១៥:០០ នាទី លោក ឡូយ សារឿន ចេញទៅក្រៅប្រជុំ មិនផ្ទេរសិទ្ធិជូនចៅសង្កាត់រងដើម្បីចេញលិខិតបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋ។ | សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ | លិខិតជូនដំណឹង | |
| ១០ | ០២២ | ០៥/១០/១៦ | ឈ្មោះ កាក់ កុម្ភារ តំណាង ហ៊ីង មុនីន្ទ ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ប្រធាន ក.ច.ប សង្កាត់ទួលស្វាយព្រៃទី២ | **កម្មវត្ថុ ៖**<br>ជំទាស់សេចក្តីជូនដំណឹងលេខ ១៦/១៦ រ.ប.ក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាសង្កាត់ទួលស្វាយព្រៃទី២។<br>**មូលហេតុ ៖**<br>ប្តឹងប្រធាន ក.ច.ប សង្កាត់ទួលស្វាយព្រៃទី២ ពីបទមិនបានបំពេញភារកិច្ចរបស់ខ្លួនក្នុងម៉ោងរដ្ឋបាល។ | សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ | កំពុងដោះស្រាយ | |
| ១១ | ០២៣ | ០៥/១០/១៦ | ឈ្មោះ កាក់ កុម្ភារ តំណាង ព្រាប ស៊ា ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ប្រធាន ក.ច.ប សង្កាត់បឹងកេងកងទី២ | **កម្មវត្ថុ ៖**<br>ជំទាស់សេចក្តីជូនដំណឹងលេខ ០២/១៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាសង្កាត់បឹងកេងកងទី២។<br>**មូលហេតុ ៖**<br>ប្តឹងប្រធាន ក.ច.ប សង្កាត់បឹងកេងកងទី២ ពីបទមិនបានបំពេញភារកិច្ចរបស់ខ្លួនក្នុងម៉ោងរដ្ឋបាល។ | សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ | កំពុងដោះស្រាយ | |
| ១២ | ០២៥ | ០៦/១០/១៦ | ឈ្មោះ ទេព ច័ន្ទខែយ៉ា | ឈ្មោះ មៅ គន្ធា ជាការីកុំព្យូទ័រ | **កម្មវត្ថុ ៖**<br>សុំប្តឹងឈ្មោះ មៅ គន្ធា ជាការីកុំព្យូទ័រនៅសង្កាត់ | សង្កាត់អូរឫស្សីទី៤ | កំពុងដោះស្រាយ | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | ទីកន្លែងកើតហេតុ | ដំណាក់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជាភ្នាក់ងារ គណបក្ស សង្គ្រោះជាតិ | សង្កាត់អូរឫស្សី ទី៤ | អូរឫស្សីទី៤ ពីបទបង្ករការស្មុគស្មាញដល់ប្រជាពលរដ្ឋក្នុងការចុះឈ្មោះបោះឆ្នោត និងច្រឡំទិន្នន័យប្រជាពលរដ្ឋ។<br>**មូលហេតុ ៖**<br>កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ ម៉ៅ គន្ធា បានបញ្ចូលលេខផ្ទះរបស់ប្រជាពលរដ្ឋឈ្មោះ ស្រី សុវណ្ណ (ភេទស្រី) និងប្រជាពលរដ្ឋឈ្មោះ ឈាង ជៀបសែ (ភេទស្រី) ច្រឡំគ្នា។ | ខណ្ឌ៧មករា រាជធានីភ្នំពេញ | | |
| ១៣ | ០២៧ | ១១/១០/១៦ | ឈ្មោះ ឈូ វីរៈខេមរា ចៅសង្កាត់រង ទី២ សង្កាត់ ទន្លេបាសាក់ នៃគណបក្ស សម រង្ស៊ី | ឈ្មោះ ខាត់ ណារិទ្ធ ជាចៅសង្កាត់ ទន្លេបាសាក់ នៃគណបក្ស ប្រជាជនកម្ពុជា | **កម្មវត្ថុ ៖**<br>ប្តឹងឈ្មោះ ខាត់ ណារិទ្ធ ជាចៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ពីបទមិនបំពេញការងារក្នុងម៉ោងរដ្ឋបាល។<br>**មូលហេតុ ៖**<br>កាលពីថ្ងៃទី០៨ ០៩ និង១០ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ ខាត់ ណារិទ្ធ ពេលព្រឹកម៉ោង ១០:២០ ទើបមកធ្វើការ និងពេលរសៀល ម៉ោង ១៦:០០ ទើបមកធ្វើការ និងមិនបានផ្ទេរសិទ្ធិជូនចៅសង្កាត់រងទៀត។ | សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | កំពុងដោះស្រាយ | |
| ១៤ | ០៣០ | ១៧/១០/១៦ | ឈ្មោះ ទេព ច័ន្ទខៃយ៉ា ជាភ្នាក់ងារ គណបក្ស សង្គ្រោះជាតិ | ឈ្មោះ អៀង សុខឃីម ចៅសង្កាត់ អូរឫស្សីទី៤ | **កម្មវត្ថុ ៖**<br>ប្តឹងឈ្មោះ អៀង សុខឃីម ចៅសង្កាត់អូរឫស្សីទី៤ ពីបទ ចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋដែលគ្មានអាសយដ្ឋានក្នុងសង្កាត់អូរឫស្សីទី៤ទេ។<br>**មូលហេតុ ៖**<br>កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៦ មានប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោតឈ្មោះ ហ្វ លីលី (ភេទស្រី) និងឈ្មោះ សាំង ស្រីខ្លីង (ភេទស្រី) អ្នកទាំងពីរមានអាសយដ្ឋានផ្ទះលេខ ២៦E2Z ផ្លូវ៩៣ សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ តាមលិខិតបញ្ជាក់ទីលំនៅដែលលោក អៀង សុខឃីម | សង្កាត់អូរឫស្សី ទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ | កំពុងដោះស្រាយ | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | ទីកន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | ចេញឱ្យនោះគឺផ្ទះលេខ២៦E2Z ផ្លូវ៥៣ មិនមាននៅក្នុងសង្កាត់អូរឫស្សីទី៤ទេ។ | | | |
| ១៥ | ០៣១ | ១៩/១០/១៦ | ឈ្មោះ យឹម សន្ថា តំណាងឱ្យឈ្មោះ ជា សុទ្ធី ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ តៅ មន្ថា ជាចៅសង្កាត់បឹងព្រលិត | **កម្មវត្ថុ ៖**<br>ប្តឹងលោកស្រីចៅសង្កាត់បឹងព្រលិត ពីបទបង្កការលំបាកដល់ប្រជាពលរដ្ឋដែលមកចុះឈ្មោះបោះឆ្នោត។<br>**មូលហេតុ ៖**<br>កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ កង ជិន (ភេទស្រី) និងសាក្សី០១នាក់ បានមកស្នើសុំលិខិតបញ្ជាក់ទីលំនៅសម្រាប់បម្រើការចុះឈ្មោះបោះឆ្នោត ប៉ុន្តែត្រូវបានលោកស្រី តៅ មន្ថា ចៅសង្កាត់បឹងព្រលិត បានបដិសេធមិនព្រមចេញលិខិតបញ្ជាក់ទីលំនៅឱ្យនោះទេ ដោយអះអាងគ្មានលិខិតជួលផ្ទះ ឬម្ចាស់ផ្ទះមិនបានឯកភាព។ | សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ | កំពុងដោះស្រាយ | |
| ១៦ | ០៣២ | ១៩/១០/១៦ | ឈ្មោះ និន រ៉ាវិន ជាប្រជាពលរដ្ឋ | ឈ្មោះ កែវ សារឿន ចៅសង្កាត់ចាក់អង្រែលើ | **កម្មវត្ថុ ៖**<br>ប្តឹងលោក កែវ សារឿន ចៅសង្កាត់ចាក់អង្រែលើ ពីបទរាំងមិនឱ្យប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោត។<br>**មូលហេតុ ៖**<br>កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៥:០០នាទី លោក ជិន វី បានទៅចុះឈ្មោះបោះឆ្នោតនៅសង្កាត់ចាក់អង្រែលើ និងបាននាំយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទៅជាមួយ នៅពេលនោះលោក កែវ សារឿន ឱ្យទៅយកលោក សម វណ្ណី មកធ្វើជាសាក្សីបានចុះឈ្មោះឱ្យ។ | សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | កំពុងដោះស្រាយ | |
| **ខេត្តព្រះវិហារ (លេខកូដ ១៣)** | | | | | | | | |
| ១ | ០០៧ | ១២/០៩/១៦ | លោក ផែង ហេង មេធាវីតំណាង លោក ពុធ | លោក ប៊ូ ឆង គ្រូបង្គោល គ.ជ.ប ប្រចាំស្រុកឆែប | **កម្មវត្ថុ ៖**<br>ប្តឹងលោក ប៊ូ ឆង ប្រើប្រាស់គំរូទម្រង់បញ្ជាជំទប់ទី២ឱ្យចេញលិខិតបញ្ជាក់ទីលំនៅ ជូនជនដែលគ្មានទីលំនៅក្នុងឃុំឆែបពីរ ។ | ឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ | លិខិតជូនដំណឹង | ផ្ញើបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | ទីកន្លែងកើតហេតុ | ដំណាក់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | សារ៉េង មេឃុំផែបពីរ មកពីគណបក្សសម រង្ស៊ី | | <u>មូលហេតុ</u> ៖<br>ពីថ្ងៃទី០៣ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ លោក បូ ឆង បានប្រើប្រាស់តួនាទីបញ្ជាលោក កែវ សាលីន ជាជំទប់ទី២ ឃុំផែបពីរ ឲ្យចេញលិខិតបញ្ជាក់ទីលំនៅជូនជនដែលគ្មានទីលំនៅក្នុងឃុំផែបពីរនេះ ដើម្បីទៅចុះឈ្មោះបោះឆ្នោត។ | | | |
| ២ | ០០៨ | ១២/០៩/១៦ | លោក ផែង ហេង មេធាវីតំណាងលោក ឃិន ខន ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | លោក កែវ សាលីន ជំទប់ទី២ ឃុំផែបពីរ មកពីគណបក្សប្រជាជន | <u>កម្មវត្ថុ</u> ៖<br>ប្តឹងលោក កែវ សាលីន ជំទប់ទី២ ឃុំផែបពីរ ពីបទចេញលិខិតបញ្ជាក់ទីលំនៅជូនជនដែលគ្មានទីលំនៅក្នុងឃុំផែបពីរ ។<br><u>មូលហេតុ</u> ៖<br>ពីថ្ងៃទី០៣ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ លោក កែវ សាលីន ជាជំទប់ទី២ ឃុំផែបពីរ បានចេញលិខិតបញ្ជាក់ទីលំនៅជូនជនដែលគ្មានទីលំនៅក្នុងឃុំផែបពីរនេះ ដើម្បីទៅចុះឈ្មោះបោះឆ្នោត។ | ឃុំផែបពីរ ស្រុកឆែប ខេត្តព្រះវិហារ | លិខិតជូនដំណឹង | |
| ៣ | ០១៥ | ១៥/០៩/១៦ | ឈ្មោះ កែវ សុផល ជាប្រជាពលរដ្ឋ | ឈ្មោះ ប៉ែន ឡាម ជាមេឃុំស្រយ៉ង់នៃគណបក្ស សម រង្ស៊ី | <u>កម្មវត្ថុ</u> ៖<br>ប្តឹងលោក ប៉ែន ឡាម មេឃុំស្រយ៉ង់ ពីបទមិនចេញលិខិតបញ្ជាក់ទីលំនៅជូនដើមបណ្តឹង។<br><u>មូលហេតុ</u> ៖<br>ពីថ្ងៃទី១២ វេលាម៉ោង ១៥:០០ លោក ប៉ែន ឡាម មេឃុំស្រយ៉ង់ បានបដិសេធមិនព្រមចេញលិខិតបញ្ជាក់ទីលំនៅជូនដើមបណ្តឹង ជាយោធាដែលមានបន្ទាយស្ថិតក្នុងទឹកដីឃុំស្រយ៉ង់ ដោយអះអាងថាដើមបណ្តឹងពុំមានសៀវភៅស្នាក់នៅក្នុងឃុំស្រយ៉ង។ | ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ | កំពុងដោះស្រាយ | |
| ៤ | ០២៦ | ០៨/១០/១៦ | ឈ្មោះ ផែង ហេង ជាមេធាវី | ឈ្មោះ ហ៊ីម ហឿន មេឃុំយាង | <u>កម្មវត្ថុ</u> ៖<br>ប្តឹងលោក ហ៊ីម ហឿន មេឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ពីបទឃុបឃិតគ្នាលួចធ្វើឯកសារខុសនិងនីតិវិធី | ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ | កំពុងដោះស្រាយ | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | ទីកន្លែងកើតហេតុ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ | គ.ជ.ប និងរៀបចំកម្លាំងសន្តិសុខសណ្តាប់ធ្នាប់ខុសនីតិវិធី និងរំលោភច្បាប់ គ.ជ.ប។<br>__មូលហេតុ__ ៖<br>ពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ ដល់សព្វថ្ងៃឈ្មោះ ហ៊ឹម ហឿន មេឃុំយាង ឃុបឃិតគ្នាជាមួយមេភូមិកំប្រាក់ ឈ្មោះ ចាន់ ហេង លួចធ្វើឯកសារនៅផ្ទះមេភូមិកំប្រាក់ដោយខុសនឹងនីតិវិធីរបស់ គ.ជ.ប។ | | | |
| **ខេត្តព្រៃវែង ( លេខកូដ ១៤)** | | | | | | | | |
| ០១ | ០២១ | ២៩/០៩/១៦ | ឈ្មោះ យ៉ុន ហ៊ាង<br>សមាជិកក្រុមប្រឹក្សាឃុំពានរោង<br>នៃគណបក្សសិទ្ធិមនុស្ស | ឈ្មោះ ស៊ឹម ខុន ភេទស្រី<br>មេឃុំពានរោង | __កម្មវត្ថុ__ ៖<br>ប្តឹងលោក ស៊ឹន ខុន ភេទស្រី ជាមេឃុំពានរោង ពីបទមិនបំពេញការងារក្នុងម៉ោងរដ្ឋបាល។<br>__មូលហេតុ__ ៖<br>កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ពេញមួយថ្ងៃ ឈ្មោះ ស៊ឹម ខុន មិនបានមកសាលាឃុំ ដើម្បីចេញលិខិតបញ្ជាក់ទីលំនៅ និង ឯ.អ ជូនប្រជាពលរដ្ឋនោះទេ។ល។ | ឃុំពានរោង<br>ស្រុកស្វាយអន្ទរ<br>ខេត្តព្រៃវែង | កំពុងដោះស្រាយ | |
| **ខេត្តសៀមរាប (លេខកូដ ១៧)** | | | | | | | | |
| ០១ | ០១០ | ១៥/០៩/១៦ | ឈ្មោះ ហ៊ុន សម្បត្តិ<br>តំណាងរដ្ឋបាលក្រុងសៀមរាប | ឈ្មោះ ស៊ុំ សារ៉ាត់ និង ជិន សុខង៉េង<br>សមាជិកគណបក្សសង្គ្រោះជាតិ | __កម្មវត្ថុ__ ៖<br>ប្តឹងលោក ស៊ុំ សារ៉ាត់ និង លោក ជិន សុខង៉េង សមាជិកគណបក្សសង្គ្រោះជាតិ ពីបទធ្វើឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ។<br>__មូលហេតុ__ ៖<br>ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ៩:០០ នាទីព្រឹក ឈ្មោះ ស៊ុំ សារ៉ាត់ និងឈ្មោះ ជិន សុខង៉េង បានដឹកនាំក្រុមយុវជនរបស់គណបក្សសង្គ្រោះជាតិ ហែក្បួន ដើម្បីផ្សព្វផ្សាយអំពីព័ត៌មានពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត។ | សង្កាត់ស្លក្រាម<br>ក្រុងសៀមរាប<br>ខេត្តសៀមរាប | លិខិតជូនដំណឹង | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចោទ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | ទីកន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ០២ | ០១១ | ១៤/០៩/១៦ | ឈ្មោះ ជិន សុខង៉េង តំណាងគណបក្សសង្គ្រោះជាតិ | ឈ្មោះ សូរ ប្លាតុង អភិបាលក្រុងសៀមរាប | <u>កម្មវត្ថុ</u> ៖<br>ប្តឹងលោក សូរ ប្លាតុង អភិបាលក្រុងសៀមរាប ពីបទរាំងប្រជាពលរដ្ឋមិនឲ្យទៅចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ៩:០០ នាទីព្រឹក ឈ្មោះ សូរ ប្លាតុង អភិបាលក្រុងសៀមរាប បានដឹកនាំកម្លាំងសមត្ថកិច្ច ទៅរាំងក្រុមយុវជនរបស់គណបក្សសង្គ្រោះជាតិហៃក្បួន ដើម្បីផ្សព្វផ្សាយអំពីព័ត៌មានពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត។ | សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | លិខិតជូនដំណឹង | |
| ០៣ | ០១២ | ១៤/០៩/១៦ | ឈ្មោះ ជិន សុខង៉េង តំណាងឈ្មោះ ចក់ នែម ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ សឿន សែន ជាជំទប់ទី១ ឃុំល្វាក្រាំង នៃគណបក្សប្រជាជនកម្ពុជា | <u>កម្មវត្ថុ</u> ៖<br>ប្តឹងលោក សែម សឿន ជំទប់ទី១ ឃុំល្វាក្រាំង ពីបទក្លែងបន្លំលិខិតបញ្ជាក់ទីលំនៅសម្រាប់បម្រើឲ្យការចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>ពីថ្ងៃទី០១ ដល់ថ្ងៃទី១២ ខែកញ្ញា តាមការពិនិត្យរបស់លោក ចក់ នែម ភ្នាក់ងារគណបក្សសង្គ្រោះជាតិ គល់បញ្ជីលិខិតបញ្ជាក់ទីលំនៅបានប្រើប្រាស់អស់តែ២១សន្លឹកទេ ប៉ុន្តែជាក់ស្តែងមានប្រជាពលរដ្ឋប្រើលិខិតបញ្ជាក់ទីលំនៅមកចុះឈ្មោះបោះឆ្នោតក្នុងឃុំល្វាក្រាំង មានចំនួនសរុប ១១៧ នាក់។ | ឃុំល្វាក្រាំង ស្រុកវ៉ារិន ខេត្តសៀមរាប | លិខិតជូនដំណឹង | |
| ០៤ | ០១៣ | ១៤/០៩/១៦ | ឈ្មោះ ជិន សុខង៉េង តំណាងឈ្មោះ គន់ ឈួប ភ្នាក់ងារគណបក្ស | ឈ្មោះ វ៉ែក ណម ជា ជំទប់ទី១ ឃុំស្រែណូយ នៃគណបក្សប្រជាជនកម្ពុជា | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ វ៉ែក ណម ភេទស្រី ជំទប់ទី១ ឃុំស្រែណូយ ពីបទក្លែងបន្លំលិខិតបញ្ជាក់ទីលំនៅសម្រាប់បម្រើឲ្យការចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>ពីថ្ងៃទី១២ ឈ្មោះ វ៉ែក ណម បានយកសៀវភៅលិខិត | ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប | លិខិតជូនដំណឹង | |

| លរ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | សង្គ្រោះជាតិ | | បញ្ជាក់ទីលំនៅដែលមានចុះហត្ថលេខា និងបោះត្រាទុកជាស្រេច ទៅឲ្យទាហានអាកាសបែកតាប់បំពេញព័ត៌មានដោយខ្លួនឯង។ | | | |
| ០៥ | ០១៧ | ២១/០៩/១៦ | ឈ្មោះ ហ៊ាង សុវណ្ណារ៉ា តំណាងឈ្មោះ យិន វណ្ណី ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ប្តឹងឈ្មោះ ទុយ លីណា ឈ្មោះ សេង សុគន្ធា ប្រធាន និងអនុប្រធាន ក.ច.ប និង ឈ្មោះ ស្រី ឆៃយ៉ា ការីកុំព្យូទ័រ សង្កាត់ស្លក្រាម | <u>កម្មវត្ថុ</u>៖<br>ប្តឹងប្រធាន អនុប្រធាន ក.ច.ប និងការីកុំព្យូទ័រ សង្កាត់ស្លក្រាម ពីបទឃុបឃិតគ្នាយកកុំព្យូទ័រចេញពីការិយាល័យ ក្នុងចេតនាឃុបឃិតគ្នាកែទិន្នន័យអ្នកបោះឆ្នោត។<br><u>មូលហេតុ</u>៖<br>ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ចុងចម្លើយទាំងបីបានយកកុំព្យូទ័រ ចេញពីការិយាល័យចុះឈ្មោះបោះឆ្នោត សង្កាត់ស្លក្រាម ទៅទុកនៅផ្ទះរបស់ឈ្មោះ ស្រី ឆៃយ៉ា ការីកុំព្យូទ័រ ដោយអះអាងថាដើម្បីធានាសុវត្ថិភាព ។ | សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | បានបដិសេធ (ដាក់ក្រោយអំឡុងពេលកំណត់) | |
| ០៦ | ០១៩ | ២៥/០៩/១៦ | ឈ្មោះ ជ កុសល តំណាងឈ្មោះ នូ ណុប ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ សេង ភិរុណ អនុប្រធាន ក.ច.ប ឃុំសំរោង | <u>កម្មវត្ថុ</u>៖<br>ប្តឹងឈ្មោះ សេង ភិរុណ អនុប្រធាន ក.ច.ប ឃុំសំរោង ពីបទបញ្ជាឱ្យការីកុំព្យូទ័រព្រីនបញ្ជីឈ្មោះអ្នកបោះឆ្នោត។<br><u>មូលហេតុ</u>៖<br>កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ សេង ភិរុណ បានបញ្ជាឱ្យការីកុំព្យូទ័រព្រីនបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃឃុំសំរោង ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឱ្យខ្លួន។ | ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប | លិខិតជូនដំណឹង | |
| ០៧ | ០២០ | ២៧/០៩/១៦ | ឈ្មោះ ជិន សុខជើង ជាប្រជាពលរដ្ឋ | ឈ្មោះ អោម ជន ចៅសង្កាត់រងទី១ សង្កាត់នគរធំ | <u>កម្មវត្ថុ</u>៖<br>ប្តឹងឈ្មោះ អោម ជន ចៅសង្កាត់រងទី១ សង្កាត់នគរធំ ពីបទមិនសហការ ដែលនាំឲ្យមានការលំបាកក្នុងការចេញលិខិតបញ្ជាក់ទីលំនៅ និង ង.អ ។<br><u>មូលហេតុ</u>៖<br>កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ លោក អោម ជន ចៅសង្កាត់រងទី១ (បានទទួលសិទ្ធិពីមេឃុំដើម្បីចេញលិខិត | សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប | លិខិតជូនដំណឹង | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | ទីកន្លែងកើតហេតុ | ដំណាក់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | បញ្ជាក់ទីលំនៅ និង ឯ.អ ) បានចេញក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ដោយយកទាំងសៀវភៅបញ្ជាក់ទីលំនៅ និងសៀវភៅបញ្ជី ឯ.អ ទៅជាមួយ។ | | | |
| ០៨ | ០២៨ | ១៨/១០/១៦ | ឈ្មោះ គង់ ម៉ាស់ តំណាងឱ្យគណបក្សសង្គ្រោះជាតិ | ឈ្មោះ លន់ រួប ជាប្រធានក្រុមប្រឹក្សាឃុំកំពង់ថ្កូវ | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ លន់ រួប ជាប្រធានក្រុមប្រឹក្សាឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ពីបទរារាំងមិនឱ្យផ្សព្វផ្សាយសាររបស់ គ.ជ.ប ដើម្បីអញ្ជើញប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៥:០០នាទី លោកមេឃុំកំពង់ថ្កូវ ឈ្មោះ លន់ រួប បានដឹកនាំកម្លាំងនគរបាលចុះទៅ រាំងក្រុមយុវជនរបស់គណបក្សសង្គ្រោះជាតិ ធ្វើការហែរក្បួននៅតាមផ្លូវសាធារណៈដើម្បីការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១៦ នៅត្រង់ចំណុចផ្លូវកែងរង្វង់មូលផ្សារក្រឡាញ់។ | ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប | កំពុងដោះស្រាយ | |
| **ខេត្តព្រះសីហនុ ( លេខកូដ ១៨)** | | | | | | | | |
| ០១ | ០១៦ | ១៦/០៩/១៦ | ឈ្មោះ វង រុន្នី ភេទស្រី ជាប្រជាពលរដ្ឋ | លោក ងួន ជាន មេឃុំជើងគោ នៃគណបក្សប្រជាជនកម្ពុជា | <u>កម្មវត្ថុ</u> ៖<br>ប្តឹងលោក ងួន ជាន មេឃុំជើងគោ ពីបទចេញលិខិតបញ្ជាក់ទីលំនៅខុសនីតិវិធី។<br><u>មូលហេតុ</u> ៖<br>ពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ លោក ងួន ជាន មេឃុំជើងគោ ចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋដែលគ្មានទីលំនៅក្នុងឃុំជើងគោចំនួន ០៥ នាក់។ | ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ | កំពុងដោះស្រាយ | |

<u>កំណត់សម្គាល់៖</u>

ក. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប សរុបមានចំនួន ៣២ បណ្តឹង (គណបក្សប្រជាជនកម្ពុជា ០៣ បណ្តឹង, គណបក្សសង្គ្រោះជាតិ ១៧ បណ្តឹង, គណបក្ស សម រង្ស៊ី ០៤ បណ្តឹង, គណបក្សសិទ្ធិមនុស្ស ០១ បណ្តឹង, អាជ្ញាធរ ០១ បណ្តឹង, ប្រជាពលរដ្ឋ ០៥ បណ្តឹង, មេឃុំ ០១ បណ្តឹង)៖

ខេត្តបាត់ដំបង ០២ បណ្តឹង (គណបក្សសង្គ្រោះជាតិ ០២ បណ្តឹង)

- កំពុងដោះស្រាយ ០២ បណ្តឹង

រាជធានីភ្នំពេញ ១៦ បណ្តឹង (គណបក្សប្រជាជនកម្ពុជា ០៣ បណ្តឹង, គណបក្ស សម រង្ស៊ី ០៣ បណ្តឹង, គណបក្សសង្គ្រោះជាតិ ០៨ បណ្តឹង, ប្រជាពលរដ្ឋ ០២ បណ្តឹង)

- កំពុងដោះស្រាយ ០៧ បណ្តឹង
- ដើមបណ្តឹងដកពាក្យបណ្តឹង ០១ បណ្តឹង
- ច្រានចោល ០២ បណ្តឹង
- លិខិតជូនដំណឹង ០៦ បណ្តឹង

ខេត្តព្រះវិហារ ០៤ បណ្តឹង (គណបក្ស សម រង្ស៊ី ០១ បណ្តឹង, គណបក្សសង្គ្រោះជាតិ ០១ បណ្តឹង, ប្រជាពលរដ្ឋ ០១ បណ្តឹង, មេឃុំ ០១ បណ្តឹង)

- កំពុងដោះស្រាយ ០២ បណ្តឹង
- លិខិតជូនដំណឹង ០២ បណ្តឹង

ខេត្តព្រៃវែង ០១ បណ្តឹង (គណបក្សសិទ្ធិមនុស្ស ០១ បណ្តឹង)

- កំពុងដោះស្រាយ ០១ បណ្តឹង

ខេត្តសៀមរាប ០៨ បណ្តឹង (គណបក្សសង្គ្រោះជាតិ ០៦ បណ្តឹង, អាជ្ញាធរ ០១ បណ្តឹង, ប្រជាពលរដ្ឋ ០១ បណ្តឹង)

- លិខិតជូនដំណឹង ០៦ បណ្តឹង
- ច្រានចោល ០១ បណ្តឹង
- កំពុងដោះស្រាយ ០១ បណ្តឹង

ខេត្តព្រះសីហនុ ០១ បណ្តឹង (ប្រជាពលរដ្ឋ ០១ បណ្តឹង)

- កំពុងដោះស្រាយ ០១ បណ្តឹង

ខ. ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ នៅ គ.ជ.ប មិនទទួលបានពាក្យបណ្តឹងទេ។

បានឃើញ និងឯកភាព
**ប្រធាននាយកដ្ឋាន**

កែវ ផល្លា

បានឃើញ និងបញ្ជូនមក
ឯកឧត្តមប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម
**អនុប្រធាននាយកដ្ឋាន**

ឌីណា សាគុណា

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦
**ប្រធានការិយាល័យ**

ហួត បូរិន